ធ៧-០១១-០០១ ស.រ.ច

# សារាចរស្តីពីការអនុវត្តប្រកាស
# ស្តីពី
# ការគណនាមូលនិធិផ្ទាល់សុទ្ធ របស់ធនាគារ

សារាចរនេះ ដាក់ចេញនូវវិធាននិងគោលការណ៍សម្រាប់អនុវត្តប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ តទៅនេះហៅថាប្រកាស ដែលចែងអំពីរចនាសម្ព័ន្ធដើមទុនថ្នាក់ទី១ និងថ្នាក់ទី២ ស្របតាមបទដ្ឋានអន្តរជាតិ។ យោងតាមប្រកាសនេះ ដើមទុនថ្នាក់ទី២ ត្រូវបានកម្រិតត្រឹមតែ ១០០% នៃដើមទុនថ្នាក់ទី១ ហើយប្រាក់ចំណេញរក្សាទុក ដែលជាសមាសភាគមួយនៃដើមទុនថ្នាក់ទី១ ត្រូវបានកំណត់ត្រឹមតែ ២០% នៃសរុបដើមទុនថ្នាក់ទី១ (ដើមទុនស្នូល ឬ ដើមទុនរឹង) ប៉ុណ្ណោះ ដើម្បីទប់ស្កាត់ភាពងាយប្រែប្រួល (Volatility) នៃដើមទុន។ ប្រកាសនេះ ក៏បានអនុញ្ញាតឱ្យគណនាបញ្ចូលសំវិធានធនទូទៅ ១% ជាសមាសភាគមួយនៃដើមទុនថ្នាក់ទី២ដែរ ពីព្រោះសំវិធានធនទូទៅនេះ ជាក់ស្តែងជាទុនបម្រុងទូទៅដែលពុំបានត្រៀមសម្រាប់ទប់ទល់ហានិភ័យជាក់លាក់ ឬហានិភ័យដែលបានកំណត់អត្តសញ្ញាណនោះឡើយ ប៉ុន្តែគឺដើម្បីជាខែលសម្រាប់ការពារសាធនភាពទូទៅ។

គ្រប់គ្រឹះស្ថានធនាគារ មានកាតព្វកិច្ចប្រតិបត្តិតាមរាល់វិធាន គោលការណ៍ ដែលមានចែងក្នុងប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

## ១.- ការត្រួតពិនិត្យផ្ទៃក្នុង និងការប្រតិបត្តិតាមជាអចិន្ត្រៃយ៍

គ្រឹះស្ថានធនាគារ ត្រូវបង្កើតគោលនយោបាយ នីតិវិធី និងដំណើរការសំដៅធានាការប្រតិបត្តិតាមជាអចិន្ត្រៃយ៍ នូវរាល់កាតព្វកិច្ចសាធនភាព និងកម្រិតកំណត់ចំពោះដើមទុន។ ពិសេសជាងនេះទៀត គ្រឹះស្ថានធនាគារត្រូវតែងតាំងបុគ្គលទទួលបន្ទុកតាមដាន និងត្រួតពិនិត្យការប្រតិបត្តិតាម ហើយត្រូវរក្សាទុកជាឯកសារនូវរាល់គោលនយោបាយ នីតិវិធី និងដំណើរការទាំងនោះ។ ជាទស្សនៈអនាគត គ្រឹះស្ថានធនាគារត្រូវវាយតម្លៃផលប៉ះពាល់ជាសក្តានុពលនៃផែនការអភិវឌ្ឍអាជីវកម្មជាយុទ្ធសាស្ត្រ និងបើចាំបាច់ត្រូវកែតម្រូវ ដើម្បីទប់ស្កាត់បញ្ហាសាធនភាព ឬការមិនគោរពតាមកម្រិតកំណត់នៃដើមទុន។ គណៈកម្មការសវនកម្មត្រូវវាយតម្លៃឡើងវិញប្រចាំគ្រានូវប្រសិទ្ធភាពនៃគោលនយោបាយ នីតិវិធី និងដំណើរការទាំងនោះ។

## ២.- កាតព្វកិច្ចរាយការណ៍

គ្រឹះស្ថានធនាគារ ត្រូវផ្តល់របាយការណ៍ប្រចាំខែអំពី មូលនិធិផ្ទាល់សុទ្ធ អនុបាតសាធនភាព ព្រមទាំងរបាយការណ៍ ដែលពាក់ព័ន្ធនឹងមូលនិធិផ្ទាល់សុទ្ធ មិនយឺតជាងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ។

គ្រឹះស្ថានធនាគារ ត្រូវប្រើគំរូរបាយការណ៍ ដូចមានភ្ជាប់មកជាមួយនៃសេចក្តីណែនាំនេះ។

## ៣.- កម្រិតកំណត់ប្រុងប្រយ័ត្ននៃប្រាក់ចំណេញរក្សាទុក និងខ្ទង់ត្រូវដកផ្សេងៗ

សេចក្តីសម្រេចណាមួយរបស់ភាគទុនិកអំពីប្រាក់ចំណេញរក្សាទុក ដែលអាចបែងចែកជាភាគលាភចំពោះភាគទុនិក អាចបង្កឱ្យមានភាពងាយប្រែប្រួលនៃដើមទុន។ ប្រាក់ចំណេញរក្សាទុកត្រូវបានកំណត់ត្រឹម ២០% នៃដើមទុនថ្នាក់ទី ១ (សរុបរង A នៅក្នុងប្រការ ៥ នៃប្រកាស) មុនពេលដកចេញសមាសភាគដូចមានរៀបរាប់នៅចំណុច II សរុបរង B (ខ្ទង់ត្រូវដកពីដើមទុនស្នូល) ។ និយាយម៉្យាងទៀត ប្រាក់ចំណេញរក្សាទុកមិនត្រូវលើសពី ២៥% (មួយភាគបួន) នៃសរុបសមាសភាគផ្សេងទៀតនៃដើមទុនថ្នាក់ទី១ ទេ។

លើសពីនេះ យោងប្រការ ៣ នៃប្រកាស ធនាគារជាតិនៃកម្ពុជាអាចជូនដំណឹងអំពីការដកចេញបន្ថែមទៀតពីដើមទុនថ្នាក់ទី១ ក្នុងគោលបំណងជាពិសេសដើម្បីស្តារឡើងវិញនូវការប្រតិបត្តិតាមការគណនាដូចមានចែងក្នុងប្រកាស។ បន្ថែមលើនេះ ផ្អែកលើរបកគំហើញនៃការត្រួតពិនិត្យដល់ទីកន្លែង ធនាគារជាតិនៃ កម្ពុជាអាចតម្រូវឱ្យបង្កើនសំវិធានធនចំពោះការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មមិនត្រឹមត្រូវ ដោយដកចេញពីមូលនិធិភាគទុនិក។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីនីតិវិធីខាងលើនេះ ហើយគ្រឹះស្ថានធនាគារត្រូវប្រតិបត្តិតាមភ្លាមរហូតដល់មានការលើកលែងជាលាយលក្ខណ៍អក្សរ។

រាល់ការដកចេញដែលពាក់ព័ន្ធ ត្រូវមានបង្ហាញច្បាស់នៅលើតារាងគណនាដោយមានយោងអធិបញ្ញា ឬសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជាចំពោះគ្រឹះស្ថានធនាគារ។ ក្នុងករណី មិនគោរពតាមប្រព្រឹត្តិកម្ម ប្រុងប្រយ័ត្ននិងរាល់ការដកចេញទេនោះ ធនាគារជាតិនៃកម្ពុជានឹងពិចារណាដាក់ពិន័យ និងមានវិធានការចំពោះគ្រឹះស្ថានធនាគារដែលល្មើស និងបើចាំបាច់ចំពោះគណៈគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារនោះ។ នៅពេលដែលទទួលបានប្រព្រឹត្តិកម្មប្រុងប្រយ័ត្ន និងការដកចេញពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារ ក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ត្រូវជូនដំណឹងភ្លាមទៅសវនករឯករាជ្យ សមាជិកគណៈកម្មការសវនកម្ម និងបុគ្គលទទួលបន្ទុកប្រតិបត្តិតាមដូចមានចែងក្នុងចំណុច ១ ខាងលើ។

## ៤.- វិធានការអន្តរកាល

ដើម្បីអនុវត្តប្រកាសប្រកបដោយប្រសិទ្ធភាព គ្រឹះស្ថានធនាគារត្រូវកោះប្រជុំមហាសន្និបាតភាគទុនិក នៅមុនថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១១ ដើម្បីសម្រេចអំពីការបែងចែកប្រាក់ចំណេញរក្សាទុកដែលបានបង្គរទុក និងដែលបានធ្វើសវនកម្ម ហើយស្របតាមកម្រិតកំណត់អំពីប្រាក់ចំណេញរក្សាទុកជាផ្នែកនៃដើមទុនថ្នាក់ទី១។

ផ្អែកលើស្ថានភាពហិរញ្ញវត្ថុ ផែនការអភិវឌ្ឍអាជីវកម្ម និងផលប៉ះពាល់ដែលបានព្យាករណ៍ទុកទៅលើស្ថានភាព និងអនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារ មហាសន្និបាតភាគទុនិកត្រូវសម្រេចអំពីការបែងចែកប្រាក់ចំណេញរក្សាទុកតាមទម្រង់ជា៖

- ការបង្វែរទៅគណនីទុនបម្រុងដែលមិនត្រូវបែងចែក
- ការបញ្ចូលទៅក្នុងដើមទុនដែលបានបង់
- ការបែងចែកភាគលាភ ឬ
- ការគួបបញ្ចូល ៣ ចំណុចខាងលើ។

## ៥.- សំណើសុំបែងចែកប្រាក់ចំណេញរក្សាទុក

គណៈគ្រប់គ្រងគ្រឹះស្ថានធនាគារ ត្រូវផ្ដល់របៀបវារៈនៃមហាសន្និបាតទៅធនាគារជាតិនៃកម្ពុជាឱ្យបាន ១០ថ្ងៃធ្វើការ មុនកាលបរិច្ឆេទមហាសន្និបាត។ របៀបវារៈមហាសន្និបាតត្រូវមានរាយលំអិតជាពិសេសដំណោះស្រាយដែលត្រូវដាក់ជូនភាគទុនិកអនុម័ត និងសំណើសុំបែងចែកប្រាក់ចំណេញរក្សាទុក។ ប្រសិនបើ សំណើដំណោះស្រាយនោះជាបញ្ហាកង្វល់ប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរចំពោះគណៈគ្រប់គ្រង អំពីកង្វល់ផ្នែកត្រួតពិនិត្យ ឬការបដិសេធដោយផ្អែកលើស្ថានភាពហិរញ្ញវត្ថុ និងជាពិសេសស្ថានភាពសាធនភាពរបស់គ្រឹះស្ថានធនាគារ ក្នុងរយៈពេល ៥ ថ្ងៃធ្វើការ បន្ទាប់ពីបានទទួលរបៀបវារៈ និងសំណើដំណោះស្រាយនោះ។ គណៈគ្រប់គ្រងត្រូវជូនព័ត៌មានទៅភាគទុនិកអំពីការបដិសេធ ឬអធិបញ្ញាប្រុងប្រយ័ត្ន បើមាន។

## ៦.- ប្រសិទ្ធភាពអនុវត្តវិធីសាស្ត្រគណនាថ្មី

នៅថ្ងៃទីមួយបន្ទាប់ពីមហាសន្និបាតភាគទុនិកដែលនឹងប្រព្រឹត្តិទៅមិនយឺតជាងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដើម្បីសម្រេចអំពីរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ចំណេញខាត សម្រាប់ឆ្នាំ២០១០ គ្រឹះស្ថានធនាគារត្រូវអនុវត្តប្រើវិធីសាស្ត្រគណនាថ្មី និងប្រើទម្រង់របាយការណ៍ដូចមានជូនភ្ជាប់។

នៅក្រោយថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ គ្រឹះស្ថានធនាគារដែលមានប្រាក់ចំណេញរក្សាទុកលើសពី ២០% នៃដើមទុនថ្នាក់ទី១ មិនត្រូវបានអនុញ្ញាតឱ្យបញ្ចូលចំណែកលើសនោះ ទៅក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធទេ។ ប្រសិនបើគ្រឹះស្ថានធនាគារនៅតែបន្តរាយការណ៍អំពីប្រាក់ចំណេញរក្សាទុកដែលលើសនោះ ធនាគារជាតិនៃកម្ពុជានឹងកែតម្រូវការគណនា និងដកចេញនូវចំណែកលើស ព្រមទាំងពិចារណាដាក់ពិន័យនិងមានវិធានការចំពោះគ្រឹះស្ថានធនាគារ និងគណៈគ្រប់គ្រង។

## ៧.- កាតព្វកិច្ចរាយការណ៍

ដើម្បីគាំទ្ររបាយការណ៍ដំបូងទាក់ទងនឹងការគណនាមូលនិធិផ្ទាល់សុទ្ធ ដែលត្រូវអនុវត្តមិនយឺតជាងថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១១ គណៈគ្រប់គ្រងមានកាតព្វកិច្ចផ្ដល់ជូនធនាគារជាតិនៃកម្ពុជានូវកំណត់ហេតុផ្លូវការនៃមហាសន្និបាតភាគទុនិក ដែលបង្ហាញច្បាស់ពីការអនុម័តបែងចែកប្រាក់ចំណេញរក្សាទុកដែលបានបង្គរ និងដែលបានធ្វើសវនកម្មស្របតាមចំណុច ៤ ខាងលើ។

បន្ទាប់ពីមហាសន្និបាតភាគទុនិកសម្រេច របាយការណ៍ហិរញ្ញវត្ថុ ការបែងចែកភាគលាភ និងការបែងចែកប្រាក់ចំណេញរក្សាទុកនៃឆ្នាំមុនៗ គណៈគ្រប់គ្រងត្រូវចេញកំណត់ហេតុផ្លូវការដែលបង្ហាញច្បាស់ពីការសម្រេចអំពីការបែងចែកផលចំណេញនិងប្រាក់ចំណេញរក្សាទុក ឬការបញ្ចូលទៅក្នុងដើមទុនដែលបានបង់ក៏ដូចជាដំណោះស្រាយផ្សេងៗដែលអាចមានផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលទៅលើស្ថានភាពសាធនភាពរចនាសម្ព័ន្ធដើមទុន និងអនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារ។

របាយការណ៍ពាក់ព័ន្ធត្រូវបានផ្ដល់ជូន ធនាគារជាតិនៃកម្ពុជាមិនយឺតជាងថ្ងៃទី៣១ ខែឧសភា រៀងរាល់ឆ្នាំ។

៨.- សេចក្តីណែនាំនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**